ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៥ អយក.សវណន

សេចក្តីណែនាំ
ស្តីពី
ការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន
នៅតាមគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សាសាធារណៈ

១. សេចក្តីផ្តើម

បំណិនជីវិត គឺជាបំណិនបញ្ញាបុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើការសម្រេចចិត្ត ការធ្វើទំនាក់ទំនង ប្រកបដោយប្រសិទ្ធភាព ព្រមទាំងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន ហើយជាបំណិនដែលរួមចំណែកក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព។

កម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន គឺជាទម្រង់មួយនៃការអប់រំដែលផ្តោតលើបំណិនរឹង និងទន់ ឬបំណិនសតវត្សរ៍ទី២១ ដូចជាការធ្វើស្ម័យឆ្លុះបញ្ចាំង ការគិតពិចារណាស៊ីជម្រៅ ការដោះស្រាយបញ្ហា និងបំណិនអន្តរបុគ្គល ជាពិសេសបំណិនជីវិតស្នូលទាំង១២ ព្រមទាំងផ្តោតលើចរិយាសម្បទារបស់សិស្សផងដែរ។ ក្នុងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស ឆ្នាំ២០១៦ បានចែងអំពីការអនុវត្តមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ហើយក៏ត្រូវបានបញ្ជាបទៅក្នុងការបង្រៀននិងរៀនមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម។ ការបង្រៀនមុខវិជ្ជាបំណិនជីវិតាមមូលដ្ឋាន តម្រូវឱ្យគ្រូបង្រៀនចេះសម្របសម្រួលឱ្យសិស្សចេះរៀនដោយខ្លួនឯង បណ្តុះទម្លាប់សិក្សាស្រាវជ្រាវ និងការសិក្សាជាក្រុម ដោយផ្សារភ្ជាប់ការរៀននៅក្នុងថ្នាក់ ឬតាមកម្មវិធីសិក្សាគ្រប់មុខវិជ្ជា ជាមួយការអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងចេះដោះស្រាយបញ្ហា។

ការអប់រំបំណិនជីវិតតាមមូលដ្ឋាន គឺជាផ្នែកមួយនៃគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០០៥-២០០៩ ដែលតម្រូវឱ្យសាលារៀនបង្រៀនទៅតាមលទ្ធភាព ២ ទៅ ៥ ម៉ោងក្នុងមួយសប្តាហ៍។ នៅឆ្នាំ ២០១៦ ការអប់រំបំណិនជីវិតតាមមូលដ្ឋាន ជាមុខវិជ្ជាមួយក្នុងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស សម្រាប់បឋមសិក្សាពីថ្នាក់ទី ៤ ដល់ថ្នាក់ទី ៦ និងមធ្យមសិក្សាពីថ្នាក់ទី ៧ ដល់ថ្នាក់ទី ៩។ នៅឆ្នាំ ២០១៨ ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍកម្មវិធីសិក្សាលម្អិតសម្រាប់មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានសម្រាប់បឋមសិក្សា និងមធ្យមសិក្សា ដែលមានរបាយម៉ោងច្បាស់លាស់ និងឯកសារណែនាំគ្រូការអប់រំបំណិនជីវិតតាមមូលដ្ឋានស្ថិតក្នុងក្របខណ្ឌសាលាកុមារមេត្រី ហើយអនុវត្តសាកល្បងនៅខេត្តគោលដៅចំនួនបី។ ឯកសារណែនាំគ្រូការអប់រំបំណិនជីវិតតាមមូលដ្ឋាន ផ្តោតលើការអភិវឌ្ឍសមត្ថភាព និងការទទួលខុសត្រូវរបស់សាលារៀន ក្នុងការអភិវឌ្ឍកម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតសាលារៀនដែលឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស និងការសិក្សាដែលផ្តោតលើបញ្ហា និងឱកាសដែលមាននៅក្នុងសហគមន៍។

ការសិក្សាមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ជួយសិស្សឱ្យជោគជ័យក្នុងជីវិត តាមរយៈការបង្រៀនពួកគេឱ្យចេះដោះស្រាយបញ្ហាពិតៗ ដែលគេជួបប្រទះ ឬឱកាសអភិវឌ្ឍអាជីពងាយដែលមាននៅតាមមូលដ្ឋាន។ បទពិសោធមួយចំនួនក្នុងការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន តាមសាលារៀនដូចជា៖

- សិស្សផ្លាស់ប្តូរឥរិយាបថ និងមានជំនឿជាក់លើខ្លួនឯង។ សិស្សសិក្សាដោយសប្បាយរីករាយ ប្រកបដោយការទទួលខុសត្រូវ ហើយស្រឡាញ់ពេញចិត្ត ព្រមទាំងអភិវឌ្ឍបំណិន និងគុណតម្លៃ ដែលជាតម្រូវការក្នុងជីវភាពរស់នៅ និងទីផ្សារការងារនៅក្នុងសតវត្សទី ២១
- គ្រូបង្រៀនប្តូរពីការបង្រៀនបែបចងចាំទៅជាការបង្រៀនបែបអ្នកវិទ្យាសាស្ត្រស្រាវជ្រាវ និងធ្វើការដោយសិក្សាពីបញ្ហាពិតជាក់ស្តែង
- សាលារៀនមានការផ្លាស់ប្តូរទាំងបរិស្ថាន និងលទ្ធផលសិក្សារបស់សិស្ស
- សហគមន៍មានការចូលរួមកាន់តែច្រើន ដោយសារសាលារៀន គ្រូ និងសិស្សបង្ហាញពីការគ្រប់គ្រង និងដឹកនាំប្រកបដោយការទទួលខុសត្រូវ តម្លាភាព គុណធម៌ និងសីលធម៌ខ្ពស់ នាំឱ្យកសាងបាននូវទំនុកចិត្តរវាងសាលារៀន និងសហគមន៍។

២. សារៈសំខាន់

- សិស្ស៖ មានសមត្ថភាព និងបំណិនសម្រាប់ការរៀនសូត្រ បំណិនលទ្ធភាពរកការងារធ្វើ បំណិនភាពអង់អាច និងភាពជាពលរដ្ឋល្អ ជាពិសេសការផ្សារភ្ជាប់ការសិក្សានៅក្នុងសាលារៀន ជាមួយនឹងការដោះស្រាយបញ្ហាផ្ទាល់ខ្លួន គ្រួសារ និងសង្គម។ ការស្ម័គ្រចិត្តសម្រាប់ការងារសហគមន៍ នឹងផ្តល់ឱកាសដល់សិស្សក្នុងការអនុវត្តចំណេះដឹងដែលគេបានរៀនក្នុងពិភពការងារ តាមរយៈការរៀនដោយធ្វើផ្ទាល់ ធ្វើការសហការ ព្រមទាំងការសាកល្បងនិងរៀនពីកំហុស។ សិស្សនឹងអភិវឌ្ឍបំណិនទន់ ភាពជាអ្នកដឹកនាំ មានទំនុកចិត្ត និងទទួលបានបទពិសោធក្នុងការងារ ដែលជាតម្រូវការសម្រាប់ការទទួលបានអាហារូបករណ៍ និងឱកាសការងារនាពេលអនាគត។ លើសពីនេះ សិស្សនឹងមានសមត្ថភាពក្នុងការលើកកម្ពស់តម្លៃផ្ទាល់ខ្លួន ភាពជាម្ចាស់ ឱកាសបង្កើតមិត្តថ្មី និងបណ្តាញការងារ ភាពរីករាយក្នុងជីវិត តម្រង់ទិសពីឱកាសការងារ
- សាលារៀន៖ លើកកម្ពស់លទ្ធផលសិក្សារបស់សិស្សលើផ្នែកទាំង៣ (វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា) និងអនុវត្តសកម្មភាពក្រៅម៉ោងសិក្សាសំដៅបង្កើន២ ម៉ោងសិក្សាយ៉ាងតិចក្នុងមួយថ្ងៃ ព្រមទាំងអនុវត្តក្របខណ្ឌកម្មវិធីសិក្សាថ្មី ២០១៦
- គ្រូបង្រៀន៖ មានសមត្ថភាពក្នុងការបញ្ជ្រាបបំណិនជីវិតមូលដ្ឋានទៅក្នុងការបង្រៀន និងរៀនមុខវិជ្ជាសំខាន់ៗ ដូចជាវិទ្យាសាស្ត្រ និងសិក្សាសង្គម ព្រមទាំងជួយសិស្សឱ្យចេះស្ម័យសិក្សា និងស្រាវជ្រាវ
- សហគមន៍៖ ផ្សារភ្ជាប់សាលារៀនជាមួយនឹងសហគមន៍ ដោយមានការចូលរួម សហគមន៍មានការអភិវឌ្ឍ មានសណ្តាប់ធ្នាប់ បង្កើនផលិតភាព និងដោះស្រាយបញ្ហាក្នុងសហគមន៍។

៣. សមាសភាគនៃកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន

កម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋានឆ្នាំ២០១៨ បានណែនាំបញ្ញត្តិថ្មីនៃបំណិនជីវិតតាមមូលដ្ឋានជាមុខវិជ្ជាកាតព្វកិច្ច។ បញ្ញតិនៃបំណិនជីវិតតាមមូលដ្ឋាន គឺជាការយកចំណេះដឹងគ្រប់មុខវិជ្ជាក្នុងកម្មវិធីសិក្សាទៅអនុវត្តជាក់ស្តែងនៅក្នុងសហគមន៍ សង្គម និងសកល ដោយកំណត់បញ្ហាដែលពួកគេជួបប្រទះ ដើម្បីរួមគ្នាដោះស្រាយ បង្កើតជាបំណិនអាជីពងាយ ការរកប្រាក់ចំណូល ការពង្រីកចំណេះដឹង ការអប់រំឥរិយាបថ និងគុណ

តម្លៃផ្ទាល់ខ្លួន។ ដូចនេះគ្រូបង្រៀនត្រូវណែនាំសិស្សឱ្យបង្កើតជាគម្រោង ឬដំណោះស្រាយ ដែលឆ្លុះបញ្ចាំងពីបរិបថក្នុងមូលដ្ឋានរបស់ពួកគេ។

តាមរយៈការចូលរួមក្នុងសកម្មភាពខាងលើ សិស្សនឹងអភិវឌ្ឍបំណិន រួមទាំងបំណិនសតវត្សទី២១។

កម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន អាចនឹងត្រូវអនុវត្តតាមរូបភាព៖

- មុខវិជ្ជាគោលក្នុងកម្មវិធីសិក្សា ដែលពាក់ព័ន្ធនឹងការរៀបចំវិធីសាស្ត្របង្រៀន ដោយមានការចូលរួម អនុវត្តសកម្មភាពក្រៅថ្នាក់ ពិពណ៌ស្នាដៃ ដើម្បីផ្សារភ្ជាប់នឹងពិភពពិតជាក់ស្តែង
- ប្រធានបទក្រៅកម្មវិធីសិក្សា ដែលជាបញ្ហាសង្គម ដូចជាការប្រែប្រួលអាកាសធាតុ ហិរញ្ញវត្ថុ យេនឌ័រ សុខភាព បរិស្ថាន អភិបាលកិច្ច សិទ្ធិមនុស្ស ។ល។
- ការអប់រំអាជីពងាយៗ ដូចជាកសិកម្ម សិប្បកម្ម សេវាកម្ម សហគ្រិនភាព និងភាពជាអ្នកដឹកនាំ។

៤. ការអនុវត្ត

នៅដើមឆ្នាំសិក្សាមុននឹងសាលារៀនបញ្ចូលកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន គណៈកម្មការគ្រប់គ្រងសាលារៀន (គគស) ត្រូវប្រជុំជាមួយគ្រប់ភាគីពាក់ព័ន្ធដើម្បី៖

៤.១-ផ្សព្វផ្សាយអំពីកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន

នាយកសាលាត្រូវចុះឈ្មោះចូលរៀនវគ្គបំណិនជីវិតតាមមូលដ្ឋាន តាមរយៈវេបសាយសាលាឌីជីថល។ នាយកសាលាត្រូវផ្សព្វផ្សាយដល់គណៈកម្មការគ្រប់គ្រងសាលារៀន សហគមន៍ និងគ្រូបង្រៀន។

៤.២-ការជ្រើសរើសប្រធានបទ

គណៈកម្មការគ្រប់គ្រងសាលារៀនរៀបចំប្រជុំកំណត់ និងជ្រើសរើសប្រធានបទ ដោយឈរលើលទ្ធផលការបំពេញការងាររបស់សាលារៀន លទ្ធផលសិក្សារបស់សិស្ស និងបញ្ហាប្រឈមនៅក្នុងសហគមន៍៖

- រៀបចំបញ្ជីប្រធានបទដែលសិស្សចង់សិក្សា និងដោះស្រាយបញ្ហាក្នុងសហគមន៍
- ភ្ជាប់ប្រធានបទដែលបានកំណត់ខាងលើជាមួយនឹងឱកាសដែលមាននៅក្នុងសហគមន៍
- កំណត់ប្រធានបទអាទិភាព
- បែងចែកប្រធានបទតាមកម្រិតថ្នាក់
- កំណត់លទ្ធភាពធនធានក្នុងសាលារៀន និងសហគមន៍ (ឯកសារ អ្នកជំនាញ ថវិកា...)
- បញ្ចូលកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋានទៅក្នុងកាលវិភាគសិក្សាប្រចាំសប្តាហ៍ និងបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ។

៤.៣-ម៉ោងសិក្សា

- អនុវត្តតាមម៉ោងសិក្សាដែលមានស្រាប់ក្នុងកម្មវិធីសិក្សា (២ ម៉ោងសិក្សាក្នុងមួយសប្តាហ៍នៅកម្រិតបឋមសិក្សា និង១ម៉ោងសិក្សាក្នុងមួយសប្តាហ៍នៅកម្រិតមធ្យមសិក្សាចំណេះទូទៅ) ដែលក្នុងម៉ោងនោះ គ្រូបង្រៀនត្រូវសម្របសម្រួលការផ្តល់ប្រធានបទ និងបទបង្ហាញលទ្ធផលរបស់សិស្ស
- អនុវត្តកម្មវិធីក្រៅម៉ោងសិក្សា ដោយអនុវត្តតាមសេចក្តីណែនាំលេខ ២៨ អយក.សណន ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២៤ សម្រាប់សិស្សធ្វើស្ម័យសិក្សា ការសិក្សាស្រាវជ្រាវ និងរៀបចំរបាយការណ៍
- បញ្ជាបវិធីសាស្ត្របង្រៀនទៅក្នុងម៉ោងសិក្សាមុខវិជ្ជាផ្សេងៗ ក្នុងសហគមន៍។

៤.៤-តារកិច្ចរបស់អ្នកពាក់ព័ន្ធ

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវចុះគាំទ្រសាលារៀន ដើម្បីពង្រឹងសមត្ថភាព និងសម្របសម្រួលការអនុវត្តរបស់សាលារៀន ជាពិសេសពិនិត្យតាមដានពីវឌ្ឍនភាពនៃការអនុវត្ត
- ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវសហការជាមួយមន្ទីរ ក្នុងការចុះគាំទ្រសាលារៀន ដើម្បីធានាថាការអនុវត្តមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ
- គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងសហគមន៍ ត្រូវចូលរួមទាំងអស់គ្នា ក្នុងដំណើរអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅតាមសាលារៀននីមួយៗ ជាពិសេសការអនុវត្តដំណាក់ទាំង ៦ នៃវិធីសាស្ត្របង្រៀន។

៤.៥-គោលការណ៍នៃការបង្រៀន

៤.៥.១-គោលការណ៍នៃការបង្រៀន

- គឺជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្សដើម្បីឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដោយប្រើប្រាស់វិធីសាស្ត្រគោលវិធីសិស្សមជ្ឈមណ្ឌល ឬវិធីសាស្ត្រចម្រុះ
- គឺជាសកម្មភាពជួយនិងលើកទឹកចិត្តសិស្សឱ្យចេះរៀនដោយខ្លួនឯងយ៉ាងសកម្ម មានប្រសិទ្ធភាព និងទទួលខុសត្រូវ ដើម្បីស្វែងយល់ ធ្វើវិចារ និងអនុវត្តចំណេះដឹង សម្រាប់ការសិក្សានិងការរស់នៅប្រចាំថ្ងៃដោយប្រើប្រាស់វិធីសាស្ត្រទំនើបដូចជាស្រាវជ្រាវ រិះរក សហការ អង្កេត និងគម្រោង
- ការបង្រៀនត្រូវបន្តពង្រឹងនិងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សា
- ការបង្រៀនត្រូវតែផ្សារភ្ជាប់ទៅនឹងដំណោះស្រាយបញ្ហានៅក្នុងបរិយាកាសជុំវិញ តាមរយៈការប្រើប្រាស់វិធីសាស្ត្រ និងសម្ភារឧបទេស រួមទាំងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍សម្បូរបែបនិងមានបច្ចុប្បន្នភាព
- ការប្រើប្រាស់ឪដ៏ថលជាមធ្យោបាយក្នុងការដោះស្រាយបញ្ហាងាយៗ និងគំនិតបង្កើតថ្មី។

៤.៥.២-លំនាំនៃការបង្រៀន និងរៀនបំណិនជីវិតតាមមូលដ្ឋាន

លំនាំនៃការបង្រៀន និងរៀនបំណិនជីវិតតាមមូលដ្ឋាន មានលក្ខណៈជាការងារគម្រោង ការសិក្សាស្រាវជ្រាវងាយៗ ការិះរក និងផ្តួចផ្តើមដោះស្រាយបញ្ហាដែលកើតមានឡើងនៅក្នុងសហគមន៍ ដោយចែករំលែកបទពិសោធ និងចំណេះដឹងទៅវិញទៅមក អភិវឌ្ឍខ្លួន និងបង្កើតថ្មី។ សិស្សក៏អាចរៀនពីអាជីវកម្មដែលមាននៅក្នុងមូលដ្ឋានក្នុងរូបភាពហាត់ការទៅតាមលំនាំដូចខាងក្រោម៖

- ស្វែងយល់ពីប្រធានបទដែលត្រូវរៀន ដែលអាចជាបញ្ហាសង្គម ឬអាជីពងាយ
- ស្រង់ព័ត៌មាន និងបទពិសោធពីសហគមន៍លើប្រធានបទដែលត្រូវរៀន
- វិភាគព័ត៌មានដោយប្រើដើមឈើបញ្ហា ដើម្បីរកដំណោះស្រាយ ឬធ្វើផែនការអាជីវកម្មចំពោះអាជីពងាយ
- អភិវឌ្ឍផែនការសកម្មភាពងាយៗ ដែលសិស្សដឹកនាំដោយមានការចូលរួមពីសហគមន៍ ឬធ្វើផែនការអាជីវកម្ម របស់ខ្លួន
- អនុវត្តផែនការសកម្មភាពនៅតាមសហគមន៍ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ឬចាប់ផ្តើមអនុវត្ត ផែនការអាជីវកម្មរបស់ខ្លួន

- ឆ្លុះបញ្ចាំងនិងវាយតម្លៃលើការបង្រៀននិងរៀនលើប្រធានបទ។

៤.៦-វិធីសាស្ត្របង្រៀន

ដើម្បីកសាងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ព្រមទាំងគុណតម្លៃ ដែលផ្សារភ្ជាប់នឹងជីវិតរស់នៅប្រចាំថ្ងៃដល់សិស្ស គ្រូបង្រៀនមានតួនាទីសម្របសម្រួលក្នុងដំណើរការបង្រៀន និងរៀន ដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌល ក្នុងការធានាការចូលរួមរបស់សិស្ស និងការអភិវឌ្ឍបំណិនទន់។ ទន្ទឹមនេះ វិធីសាស្ត្របង្រៀនបំណិនជីវិតតាមមូលដ្ឋាន មានដំណាក់កាលទាំង៦ ដូចខាងក្រោម៖

- ដំណាក់កាលទី១ ស្វែងយល់ប្រធានបទ ដោយកំណត់បាននូវអ្វីដែលសិស្សចេះស្រាប់ និងមធ្យោបាយនានា ដើម្បីបង្កើនចំណេះដឹងរបស់សិស្សចំពោះប្រធានបទដែលបានជ្រើសរើស
- ដំណាក់កាលទី២ ប្រមូលព័ត៌មាន ដោយបង្កើតឧបករណ៍ និងចុះប្រមូលព័ត៌មានពីសហគមន៍ ដែលអាចឱ្យសិស្សវាយតម្លៃការយល់ដឹង និងឥរិយាបថរបស់ពួកគេលើប្រធានបទដែលបានជ្រើសរើស
- ដំណាក់កាលទី៣ វិភាគព័ត៌មាន តាមរយៈការប្រើប្រាស់ព័ត៌មានដែលប្រមូលបាន ដើម្បីវិភាគបញ្ហាសំខាន់ៗដូចជាមូលហេតុ ផលវិបាក និងដំណោះស្រាយចំពោះបញ្ហានោះ ដោយប្រើដំណើរការវិភាគតាមបែបដើមឈើបញ្ហា
- ដំណាក់កាលទី៤ អភិវឌ្ឍផែនការផ្សព្វផ្សាយ ដោយកំណត់ដំណោះស្រាយដែលអាចអនុវត្តជាក់ស្តែង (មួយ ឬច្រើន) ដើម្បីដោះស្រាយបញ្ហា និងកសាងផែនការសម្រាប់អនុវត្ត
- ដំណាក់កាលទី៥ អនុវត្តផែនការសកម្មភាព ដែលសិស្សមានសមត្ថភាពអនុវត្តតាមដំណោះស្រាយដែលគេជ្រើសរើសជាទម្រង់ សកម្មភាព ផ្សព្វផ្សាយ និងចូលរួម ដើម្បីដោះស្រាយបញ្ហាដែលមាននៅតាមមូលដ្ឋាន
- ដំណាក់កាលទី៦ ឆ្លុះបញ្ចាំង និងវាយតម្លៃ ដោយលើកទឹកចិត្តសិស្ស ឱ្យធ្វើការឆ្លុះបញ្ចាំង និងរៀនសូត្រពីបទពិសោធក្នុងការអនុវត្តសកម្មភាពផ្សព្វផ្សាយនៅតាមមូលដ្ឋាន។

៥. ការចូលរួម និងការគាំទ្រ

- គ្រប់នាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវសម្របសម្រួល និងចុះគាំទ្រការអនុវត្តនៅតាមសាលារៀន ជាពិសេសការអភិវឌ្ឍសមត្ថភាពសាលារៀន ដើម្បីអាចអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋានបាន និងទទួលបានលទ្ធផលល្អ
- ដៃគូអភិវឌ្ឍទាំងអស់ សូមបន្តការគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសសាលារៀន លើការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ទាំងការអភិវឌ្ឍសមត្ថភាព ការគាំទ្រសាលារៀន និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន
- គ្រប់អ្នកពាក់ព័ន្ធ ជាពិសេសសាលារៀន អាចប្រើប្រាស់ឯកសារ ដែលមានក្នុងតំណភ្ជាប់ និង QR Code ខាងក្រោមនេះ ដើម្បីជាជំនួយបច្ចេកទេសដល់ការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន៖

https://drive.google.com/drive/mobile/folders/1DIKe-5zaiZQ5X4VX95UqA9kXOTdG49eZ?usp=sharing

➢ កម្មវិធីសាលាកុមារមេត្រី ឯកសារណែនាំគ្រូ ការអប់រំបំណិនជីវិតតាមមូលដ្ឋាន ឆ្នាំ២០១៨

- ឯកសារណែនាំអនុវត្ត សម្រាប់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន ការអនុវត្តបំណិនជីវិតក្នុងបរិបទ ជីវិតរស់នៅជាក់ស្តែង ឆ្នាំ២០១៩
- សៀវភៅណែនាំអនុវត្តសម្រាប់សាលារៀន ស្តីពីបំណិនជីវិតតាមមូលដ្ឋាន ឆ្នាំ២០២៤
- សៀវភៅយោងសម្រាប់បំណិនជីវិតតាមមូលដ្ឋាន ឆ្នាំ២០២៤ (ធនធានឯកសារ)។ល។

៦. ការគ្រប់គ្រងការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន

- នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ត្រូវចាត់ចែងជនបង្គោល ឬការិយាល័យជំនាញ ព្រមទាំងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីដឹងថាសាលារៀន គ្រូបង្រៀន សិស្ស និងប្រធានបទដែលបានអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវចាត់ចែងជនបង្គោល ឬការិយាល័យជំនាញ ព្រមទាំងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីដឹងថាសាលារៀន គ្រូបង្រៀន សិស្ស និងប្រធានបទដែលបានអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន
- ក្រសួង មន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រប់អ្នកពាក់ព័ន្ធ ត្រូវរៀបចំផែនការច្បាស់លាស់ក្នុងការជំរុញការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន។

៧. ការពិនិត្យតាមដាន និងវាយតម្លៃ

អង្គភាពពាក់ព័ន្ធ មន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន ត្រូវរៀបចំប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី ដោយផ្សារភ្ជាប់នឹងស្តង់ដាសាលារៀនគំរូ។

ការវាយតម្លៃបំណិនដែលសិស្សបានអភិវឌ្ឍ គឺជាការវាយតម្លៃមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានផ្តោតលើវឌ្ឍនភាពរបស់កុមារអំពី វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទានិងគុណតម្លៃផ្ទាល់ខ្លួន។ ការវាយតម្លៃមានរូបភាពពីរ៖ ១) វាយតម្លៃក្រៅផ្លូវការ និង ២) វាយតម្លៃផ្លូវការ។ ការវាយតម្លៃក្រៅផ្លូវការជាស្វ័យវាយតម្លៃរបស់សិស្សខ្លួនឯង ពីមិត្តភក្តិ ពីក្រុម និងការសង្កេតពីគ្រូផងដែរ។ ការវាយតម្លៃផ្លូវការមានពីផ្នែក៖ ១) តេស្តសរសេរវាយតម្លៃចំណេះដឹង ដែលសិស្សយកមកអនុវត្តសម្រាប់ខ្លួនឯង គ្រួសារ និងសហគមន៍ និង ២) តេស្តប្រតិបត្តិដែលតម្រូវឱ្យសិស្សធ្វើសកម្មភាពឆ្លើយតបទៅនឹងបំណិនមួយចំនួនក្នុងចំណោមបំណិនស្នូលទាំង១២។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង**គណៈគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សានិងមធ្យមសិក្សាសាធារណៈ** បុគ្គលិកអប់រំ មាតាបិតា ឬអ្នកអាណាព្យាបាលគ្រប់រូប ត្រូវអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃចន្ទ ៣ កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

កន្លែងទទួល៖
- រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី «ដើម្បីជូនជ្រាបជាព័ត៌មាន»
- រដ្ឋបាល ក្រុង ស្រុក ខណ្ឌ
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត «ដើម្បីអនុវត្ត»
- កាលប្បវត្តិ.ឯកសារ នាយកដ្ឋានបឋមសិក្សា